# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីស្ថានសួគ៌ក្នុងព្រះពុទ្ធសាសនា

web site: hoksavann.org

ថ្ងៃទី១ ឧសភា ២០០៥

ស្ថានសួគ៌និងអ្នកដែលទៅកើតនៅស្ថានសួគ៌ ដែលមាននិយាយក្នុងព្រះពុទ្ធសាសនា គឺជាតួព្រះពុទ្ធដីកា ពុំមែនអដ្ឋកថាសំដែងទេ ហើយស្ថានសួគ៌និងអ្នកដែលទៅកើតក្នុងទីនោះ គឺកើតឡើងដោយកុសលកម្មដែលមនុស្សសត្វបានកសាង ពុំមែនកើតឡើងពីព្រះម្ចាស់អង្គណាបង្កើតឡើង សំរាប់ផ្តល់រង្វាន់ឲ្យដល់អ្នកជឿឡើយ ។ ពាក្យថាសួគ៌ឬឋានសួគ៌នេះ ជាពាក្យខ្មែរដែលចេញពីភាសាសំស្រ្កឹតថា សគ៌: បាលីថា សគ្គ: ដែលចែកចេញជាពីរពាក្យ គឺ<ស>មួយបទ និង<គ្គ>មួយបទ ។ <ស> សព្ទដើមជា<សុ>ប្រែថាល្អ ស្អាត ឬងាយ ឯ <គ្គ> សព្ទដើមជា <អគ្គ:> ប្រែថាចុងកំពូល ឬ លើស ។ រួមពាក្យទាំងពីរគឺ <ស>និង<គ្គ> ជា <សគ្គ:> ប្រែថាល្អលើស ស្អាតលើស ងាយលើស គឺល្អ ស្អាត ងាយ លើសផ្លូវលោក ដោយរូបសម្លេង ក្លិន រសសម្ផស្ស ទ្រព្យ យស សុខ សរសើរ អាយុ ពណ៌សម្បុរ ជាដើម ។ ស្ថានសួគ៌ក៏ដូចស្ថាននរកដែរ មាននិយាយក្នុងគម្ពីរព្រះត្រៃបិដក ជាគម្ពីរដ៏ធំរបស់ព្រះពុទ្ធសាសនា ។ ពួកទេវតានិងស្ថានសួគ៌ ត្រូវព្រះពុទ្ធសំដែងដោយផ្ទាល់ រួចអដ្ឋកថាយកមកសំដែងពង្រីកសេចក្តីបន្ថែមទៀត ។ ក្នុងកាមាវចរកុសលមាននិយាយពីស្ថានសួគ៌៦ជាន់ ហើយថាព្រះពុទ្ធបានយាងទៅប្រោសពុទ្ធមាតានៅស្ថានត្រៃត្រឹង្ស ជាស្ថានសួគ៌ជាន់ទី២ផង ។ ពុទ្ធកិច្ច៥របស់ព្រះពុទ្ធមាននិយាយថាពេលពាក់កណ្តាលអាធ្រាត្រស្ងាត់ ព្រះអង្គបានដោះស្រាយប្រស្នារបស់ពពួកទេវតាទាំងឡាយ ដែលបានមកសាកសួរព្រះអង្គ ដូចមានក្នុងសូត្រជាច្រើន មានមង្គលសូត្រជាដើម ។ នៅក្នុងព្រះសូត្រទាំងនោះ ក៏មានពាក្យរបស់ទេវតាដែលបញ្ចេញទស្សនៈរបស់ខ្លួន ដែលហៅថាទេវតាសុភាសិត ហើយព្រះពុទ្ធបានពោលតែពាក្យរបស់ទេវតាទាំងនោះផង ។

មនុស្សសត្វដែលបានកើតក្នុងស្ថានសួគ៌ ដោយបានប្រព្រឹត្តតាមទេវធម៌គឺធម៌សំរាប់កើតជាទេវតា ។ ទេវធម៌គឺអ្នកមានហិរិឱត្តប្ប:ល្អាសបាបខ្លាចបាបមិនហ៊ានធ្វើ អ្នកមានសីល៥ មានការមិនសម្លាប់សត្វ បំបាត់ជីវិតគេជាដើម ។ អ្នកបំរើមាតាបិតាឲ្យគាត់រស់នៅបានសុខស្រួល ព្រមទាំងញ៉ាំងគាត់ឲ្យស្ថិតនៅក្នុងសទ្ធាសម្បទា សីលសម្បទា ចាគសម្បទា និងបញ្ញាសម្បទា ។ ធ្វើទានរក្សាសីល គោរពសាមណ:អ្នកមានគុណធម៌មានសីលគុណជាដើម ។ ធ្វើសាធារណ:ប្រយោជន៍ដល់ជនដទៃ ដោយការអាណិតអាសូរចំពោះជនដែលមានសេចក្តីទុក្ខលំបាក ។

ចំពោះសំនួរថា បើស្ថានសួគ៌មានពិតមែន តើស្ថិតនៅទីណា ព្រោះគេពុំឃើញមាននៅក្នុងផែនទីពិភពលោកឡើយ ។ តាមពិតស្ថានសួគ៌ផ្សេងពីស្ថានមនុស្ស តែស្ថិតនៅលើដីជាមួយមនុស្ស ។ ស្ថានសួគ៌៦ជាន់ក្នុងកាមលោក ស្ថានព្រហ្មមានរូប១៦ជាន់ ជារូបព្រហ្ម និងអរូបព្រហ្ម៤ជាន់ ស្ថិតនៅទាក់ទងនឹងផែនដី ។ ក៏ដូចគ្នានឹងរុក្ខទេវតា គឺទេវតាអាស្រ័យនៅនឹងដើមឈើ ភុម្មទេវតា គឺទេវតាស្ថិតនៅអាស្រ័យដីស្រែចំការសុទ្ធស្ថិតនៅទាក់ទងនឹងផែនដី ។ ធម៌សគ្គេកាមា ដែលព្រះសង្ឃសូត្រពេលចំរើនព្រះបរិត្ត បកប្រែថា ទេវតាទាំងឡាយដែលស្ថិតនៅក្នុងស្ថានសួគ៌ ដែលជាកាមភពនិងរូបភពក្តី ភូមទេវតាទាំងឡាយ ដែលស្ថិតនៅក្នុងទិព្វវិមាន គឺលើកំពូលភ្នំ ឬភ្នំដែលដាច់ក្តី ព្ធដ៏អាកាសក្តី នៅនាកោះនិងដែននិងស្រុកក្តី នៅនាដើមព្រឹក្សានិងព្រៃញាតល្បាតឬទីស្រែចំការក្តី ប៉ុណ្ណោះជាដើមបញ្ជាក់ថា ទេវតាស្ថិតនៅទាក់ទងនឹងផែនដី ។ មនុស្សពុំអាចមើលឃើញពួកទេវតាទាំងនោះដោយមំសចក្ខុ គឺសាច់ភ្នែកធម្មតាបានឡើយ ព្រោះមានធាតុខុសគ្នា ប៉ុន្តែគេអាចឃើញឬដឹងបាន តាមរយ:ការអប់រំផ្លូវចិត្តតាមវិធីសមថ:និងវិបស្សនា រហូតកើតទិព្វចក្ខុផ្នែកអភិញ្ញា ។ ពួកទេវតាត្រូវផុតវិស័យវិទ្យាសាស្រ្ត ដែលអាចពិសោធន៍ឃើញតាមភ្នែកធម្មតា ឬតាមឧបករណ៍អតិសុខុមទស្សន៍ ។ មានសេចក្តីបញ្ជាក់ក្នុងព្រះអភិធម្មនៃគម្ពីរព្រះពុទ្ធសាសនាថា កាមាវចរសត្វ មុននឹងដាច់ខ្យល់ស្លាប់ ត្រូវតោងយកនិមិត្ត៣ និមិត្តណាមួយដើម្បីចាប់បដិសន្ធិ គឺកម្ម, កម្មនិមិត្ត និងគតិនិមិត្ត ។ គតិនិមិត្តផ្នែកកុសល ឃើញទេវតាយករាជរថមកទទួល ឮសម្លេងដូរ្យដន្រ្តី លុះមនុស្សស្លាប់ទៅ ក៏ទៅកើតជាទេវតា ។

មានសេចក្តីតំណាលក្នុងជាតកថា ភិក្ខុមួយអង្គបានចំរើនធម៌ កើតទិព្វចក្ខុ ក្រឡេកមើលលើផែនដី ឃើញវិមានទេវតានៅពាសពេញកាលពុំទាន់កើតទិព្វចក្ខុ គ្មានឃើញវិមានទាំងនោះសោះ ។ ព្រះនាមរបស់ព្រះពុទ្ធមួយបទថា លោកវិទូ ប្រែថាព្រះអង្គជ្រាបច្បាស់នូវលោក គឺជ្រាបនូវមនុស្សលោក ទេវលោក យមលោកគឺនរក និងព្រហ្មលោក ។ គេពុំអាចបដិសេធថា គ្មាននូវអ្វីដែលខ្លួនពុំបានឃើញនោះឡើយ ព្រោះរបស់ខ្លួនមានពិតតាមសភាពខ្លួនវា មានស្ថានសួគ៌ស្ថាននរកជាដើម ប៉ុន្តែមើលពុំឃើញដោយខ្វះសមត្ថភាពដែលនាំឲ្យមើលឃើញ ។ អ្នកខ្លះយល់ថា អ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ មានវិទ្យា មានបុណ្យស័ក្តិ មានអំណាចនោះឯងជាទេវតាជាស្ថានសួគ៌ ។ តាមពិត ក្នុងពុទ្ធសាសនាមាននិយាយអំពីពាក្យសម្មតិទេព គឺទេវតាដែលសន្មតិនោះ សំដៅយកអ្នកមានធម៌ក្នុងខ្លួន មានហិរិឱត្តប្ប: ខ្មាសបាបខ្លាចបាប ប្រព្រឹត្តទេវធម៌ជាធម៌ទេវតានៅលើផែនដីនៃមនុស្សលោក ។ ឯពាក្យមួយទៀតគេហៅថា ឧបត្តិទេព គឺទៅកើតជាទេវតាក្នុងស្ថានសួគ៌ បន្ទាប់ពីអ្នកនោះស្លាប់ទៅ ។ ចំណែកអ្នកមានទ្រព្យសម្បត្តិស្តុកស្តម្ភ មានអំណាចបុណ្យស័ក្តិខ្ពង់ខ្ពស់ បើរបស់និងអំណាចទាំងនោះបានមកដោយអំពើទុច្ចរិត គ្មានហិរិឱត្តប្ប:ទេ នោះពុំមែនជាអំពើប្រព្រឹត្តទៅដើម្បីស្ថានសួគ៌ទេ គឺជាអំពើប្រព្រឹត្តទៅដើម្បីស្ថាននរកវិញទេ ។ ដូច្នេះស្ថានសួគ៌ពិតជាសំរាប់អ្នកសាងកុសល ក៏ដូចជានរកពិតជាមានសំរាប់អ្នកសាងអកុសល ដែលស្ថិតនៅទាក់ទងនឹងផែនដី ដែលមនុស្សពុំអាចមើលឃើញឡើយ ។ ស្ថានសួគ៌៦ជាន់ខ្ពស់ទាបជាងគ្នាដោយឋាន:គឺ បុណ្យកុសលដែលខ្លួនបានកសាង ពុំមែនខ្ពស់ទាបដោយទីកន្លែងឡើយ ។ ឯរុក្ខទេវតា អាកាសទេវតា ភុម្មទេវតាមានបុណ្យតិចជាងទេវតា៦ជាន់ខាងលើនេះ ។ ដូចមនុស្សបច្ចុប្បន្ននេះ អ្នកធំអ្នកតូចអ្នកមានអ្នកក្រ ស្ថិតនៅលើដីដូចគ្នា ប៉ុន្តែបើនិយាយពីឋាន:មានលក្ខណ:ខុសៗគ្នា ។ ចំពោះទេវតា៦ជាន់ដែលហៅថាទេវតាក្នុងឆកាមាសួគ៌៦ជាន់ គឺទេវតាស្ថិតនៅជាន់ចាតុម្មហារាជិកា តាវត្តឹង្ស យាមា តុសិត និម្មានរតី និង បរនិម្មិតវសវត្តី ថានៅលើភ្នំព្រះសុមេរុនោះ មានអ្នកខ្លះបញ្ចេញទស្សនៈថា តើស្ថានសួគ៌និងទេវតាទាំងនោះស្ថិតនៅនិងរស់នៅដូចម្តេចកើត បើទីនោះមានសុទ្ធតែទឹកកកបានអ្វីទទួលទាន ។ ទស្សនៈនេះគេដោះស្រាយទេវតាដូចជាមនុស្ស តាមពិតទេវតាសោយទិព្វសម្បត្តិ ទាំងទីកន្លែង ទាំងចំណីអាហារ ទាំងការសប្បាយនិងកាមគុ-

ណា ពុំមែនដូចមនុស្សទេ ។ បើស្ថានសួគ៌៦ជាន់នោះស្ថិតនៅលើភ្នំព្រះ ជាស្ថានមួយផ្សេងដែលភ្នែកធម្មតាមើលពុំឃើញ ដូច្នេះមិនត្រូវយកភ្នែកសុមេរុពិតមែននោះ ពុំមែនស្ថិតនៅលើភ្នំតាមភ្នែកមើលឃើញនោះទេ គឺ ធម្មតាមកដោះស្រាយបដិសេធនូវភាពអាចកំបាំងនេះឡើយ ។៚